**គម្រោងបន្ទាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាព ជុំវិញតំបន់ទន្លេសាប**

TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ






វដ្តផលិតកម្មកូនមាន់

ខែវិច្ឆិកា ឆ្នាំ២០១១

## សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក បានផ្តល់នូវចំណូលបន្ថែមជាប្រចាំខែដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ។ ទន្ទឹមនឹងការចិញ្ចឹមនេះ កសិករនៅតែអាចប្រកបរបរ ឬការងារផ្សេងទៀតបាន។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមមាន់មេ និងបា ២១ក្បាល (មេ ១៨ និង បា ៣) អាចទទួលផលពីការលក់មាន់ចំនួន ៥០គីឡូ ក្នុង១ខែៗ ហើយបានចំណូលសរុបជាមធ្យម ៨០ ម៉ឺនរៀល ។ កសិករអាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ពី ៣០ ទៅ ៣៥ ម៉ឺនរៀល ក្នុង ១ខែៗ ។ ប្រាក់ចំណូលនេះ នឹងកើនឡើងបន្ថែមទៀត បើ កសិករបង្កើនចំនួនមេបាមាន់ ។ តាមបច្ចេកទេសចិញ្ចឹមថ្មីនេះ មេមាន់ ១ក្បាល អាចផលិតកូនបានពី ៦ ទៅ ៧សំបុក ក្នុង ១ឆ្នាំ ហើយកូនមាន់មិនងាប់ ចិញ្ចឹមបានរស់ដល់ធំ ក្នុងរយៈពេលតែ ១០៥ថ្ងៃ ដែលមានទម្ងន់ជាមធ្យម ១,២ គីឡូក្រាម ក្នុង ១ ក្បាល ។

## តើធ្វើដូចម្តេចដើម្បីឲ្យការចិញ្ចឹមមាន់ទទួលបានជោគជ័យ ?

### ១. ការរៀបចំទ្រុងសម្រាប់ចិញ្ចឹម

#### ក. ទ្រុងមេបា និងមាន់បំប៉នសាច់សម្រាប់លក់




- សាងសង់ទ្រុងមាន់លើដីមិនលិចទឹក
- តួរពោងមានបណ្តោយ ១០ម និងទទឹង ៥ម ចែកជា ៨ បន្ទប់ (បន្ទប់ទល់ខ្នងគ្នា)
- សសរកន្ទោងកំពស់ ៣,២ម និងជើងរៀង ១,៧ម
- តួពោងព័ទ្ធដោយសំណាញ់ និងចែកខ័ណ្ឌជាបន្ទប់ៗ



- ខាងក្នុង មានផ្ទើរ សម្រាប់ឱ្យមាន់ទំដេក
- តសំយ៉ាបពោងដាក់ទ្រុងកូន និងថែរក្សាកូនមាន់ដែលទើបញាស់

#### ខ. ទ្រុងថែរក្សាកូនមាន់ទើបញាស់










### ២. ស្នូកចំណី និង ស្នូកទឹក

- ត្រូវដាក់ស្នូកទឹក និងចំណី ឲ្យបានច្រើន គ្រប់គ្រាន់
- ស្នូកចំណី អាចច្នៃធ្វើពី ប៊ីដុង ឬ កានដ័រតូចធំ









### ៣. តើពូជមាន់ស្រុកបែបណា សមស្របសម្រាប់ការចិញ្ចឹម ?

- សុខភាពល្អ
- មាឱធំ ជើងលឿង
- មេនិងបាមិនជាប់ខ្សែស្រឡាយនឹងគ្នា
- បាពូកែជាន់មេ





- បា១ក្បាល ត្រូវដាក់បង្កាត់ជាមួយមេចំនួនពី ៦ ទៅ ៧ក្បាល

*ចំណាំ:* មិនត្រូវទុកមេ និងបាចិញ្ចឹម ទាល់ចាស់មានអាយុលើសពី ៣ឆ្នាំ